# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៤៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកបារាយណ៍ នៃខេត្តកំពង់ធំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ១៣៧ គជប.សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីបេក្ខជនជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកបារាយណ៍ នៃខេត្តកំពង់ធំ អាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

១- លោក **ស៊ីន សំឮ** ជាប្រធានក្រុមប្រឹក្សាស្រុក

Downloaded from http://www.khmerlaws.com

២- លោក ថ៊ុន ឈួន ជាសមាជិកក្រុមប្រឹក្សាស្រុក

៣- លោក ចិក សារឿន ជាសមាជិកក្រុមប្រឹក្សាស្រុក

៤- លោក ស៊ិន សេងឈីម ជាសមាជិកក្រុមប្រឹក្សាស្រុក

៥- លោក គីម សារឿន ជាសមាជិកក្រុមប្រឹក្សាស្រុក

៦- លោក គីម សុខេន ជាសមាជិកក្រុមប្រឹក្សាស្រុក

៧- លោក ម៉ុក សឿង ជាសមាជិកក្រុមប្រឹក្សាស្រុក

៨- លោក ម៉ម សុក ជាសមាជិកក្រុមប្រឹក្សាស្រុក

៩- លោក ឆាយ សិន់ ជាសមាជិកក្រុមប្រឹក្សាស្រុក

១០- លោក អ៊ុំ ឆាន ជាសមាជិកក្រុមប្រឹក្សាស្រុក

១១- លោកស្រី សោម សិរីវឌ្ឍិយ៉ាន ជាសមាជិកក្រុមប្រឹក្សាស្រុក

១២- លោក ហួយ ឈាងស៊ីម ជាសមាជិកក្រុមប្រឹក្សាស្រុក

១៣- លោក សុះ សូនី ជាសមាជិកក្រុមប្រឹក្សាស្រុក

១៤- លោក គន សុភាព ជាសមាជិកក្រុមប្រឹក្សាស្រុក

១៥- លោក សំ សុជាតិ ជាសមាជិកក្រុមប្រឹក្សាស្រុក

១៦- លោក ឈិន សុខា ជាសមាជិកក្រុមប្រឹក្សាស្រុក

១៧- លោក គុល សារឿន ជាសមាជិកក្រុមប្រឹក្សាស្រុក

១៨- លោកស្រី អ៊ុំ ដាវី ជាសមាជិកក្រុមប្រឹក្សាស្រុក

១៩- លោក ស៊ីម សារីន ជាសមាជិកក្រុមប្រឹក្សាស្រុក ។

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់ បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកបារាយណ៍ នៃខេត្តកំពង់ធំ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**__កន្លែងទទួល :__**

*ក្រសួងព្រះបរមរាជវាំង*
*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*អគ្គលេខាធិការរាជរដ្ឋាភិបាល*
*ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
*(ដើម្បីជូនជ្រាប)*
*ដូចមាត្រា ៥*
*ឯកសារ កាលប្បវត្តិ*

Downloaded from http://www.khmerlaws.com